# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

លេខ: ០៥៤ គ.ជ.ប.ស.ស.ក

## សេចក្តីសម្រេច
## ស្តីពី
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាព ចំពោះសមាជិក សមាជិកា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

## គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣១៥/០០២ ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៥/៣២៧ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៥ ស្តីពីការតែងតាំងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៧/១១៦៩ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៧ ស្តីពីការតែងតាំងអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជំនួសអនុប្រធាន និងសមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដែលបានលាឈប់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១១៧/១១០៧ ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១៧ ស្តីពីរបបសោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពនៃសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- យោងស្មារតីអង្គប្រជុំគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ថ្ងៃទី៩ ខែមីនា ឆ្នាំ២០១៨។

## សម្រេច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

**ប្រការ ១.-**

សេចក្តីសម្រេចនេះ មានគោលបំណងកំណត់អំពីលក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់សោធននិវត្តន៍ចំពោះសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នៅពេលចប់អាណត្តិដល់អាយុចូលនិវត្តន៍ដែលមិនត្រូវបានជ្រើសតាំងបន្តទៀត និងប្រាក់ឧបត្ថម្ភមរណភាពចំពោះសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានទទួលមរណភាព។

**ប្រការ ២.-**

សេចក្តីសម្រេចនេះ មានវិសាលភាពអនុវត្តចំពោះសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ជំពូកទី ២
## លក្ខខណ្ឌ បែបបទ និងនីតិវិធីនៃការផ្តល់ប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាព

### ផ្នែកទី ១
### លក្ខខណ្ឌនៃការផ្តល់ប្រាក់សោធននិវត្តន៍

**ប្រការ ៣.-**

សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលប្រាក់សោធននិវត្តន៍បាន លុះត្រាតែបានបំពេញលក្ខខណ្ឌ ដូចខាងក្រោម៖

- ជាសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងអាណត្តិមួយ ឬច្រើន គិតចាប់ពីឆ្នាំ១៩៩៨ មក
- មានអាយុចាប់ពី ៦០ ឆ្នាំឡើង
- មិនបានទទួលប្រាក់សោធននិវត្តន៍ពីក្រសួង ស្ថាប័នណាមួយរបស់រដ្ឋទេ
- យល់ព្រមបោះបង់ប្រាក់សោធននិវត្តន៍ពីក្រសួង ស្ថាប័នណាមួយ បើមាន
- ត្រូវធ្វើពាក្យសុំចូលនិវត្តន៍។

**ប្រការ ៤.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែរបស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវគណនាតាមសន្ទស្សន៍ ដូចមានចែងក្នុងប្រការ៦នៃសេចក្តីសម្រេចនេះ ហើយត្រូវរៀបចំ និងកែសម្រួលរៀងរាល់នីតិកាលនីមួយៗនៃរដ្ឋសភា ដោយផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងដែលសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបានទទួលនៅក្នុងរយៈពេលមួយឆ្នាំនៃឆ្នាំណាមួយ ដែលមានចំនួនទឹកប្រាក់ខ្ពស់បំផុតក្នុងនីតិកាលនៃរដ្ឋសភានោះ។ ចំនួនទឹកប្រាក់សរុបមួយឆ្នាំដែលខ្ពស់បំផុតនេះ ត្រូវបានកំណត់ស្មើ ១០០ (មួយរយ) ភាគរយ។

**ប្រការ ៥.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែនៃសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សម្រាប់នីតិកាលថ្មីនៃរដ្ឋសភា ត្រូវផ្អែកលើប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗ គ្រប់យ៉ាងដែលសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលបានខ្ពស់បំផុតនៅក្នុងឆ្នាំណាមួយក្នុងនីតិកាលនៃរដ្ឋសភាដែលបានបញ្ចប់រួចទៅហើយ។

**ប្រការ ៦.-**

ប្រាក់សោធននិវត្តន៍ប្រចាំខែត្រូវកំណត់ដោយផ្អែកលើរយៈពេលបំពេញការងារ ដូចតទៅ៖

- ពី ១ ឆ្នាំ ដល់ ៣ ឆ្នាំ ទទួលបានសន្ទស្សន៍ ០,៥%
- លើសពី ៣ ឆ្នាំ ដល់ក្រោម ៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ១%
- ពី ៦ ឆ្នាំ ដល់ក្រោម ១១ ឆ្នាំ ទទួលបានសន្ទស្សន៍ ២%
- ពី ១១ ឆ្នាំ ដល់ក្រោម ១៦ ឆ្នាំ ទទួលបានសន្ទស្សន៍ ៣%
- ពី ១៦ ឆ្នាំឡើងទៅ ទទួលបានសន្ទស្សន៍ ៤%
- ចំពោះសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងតំណែង ៣ (បី) អាណត្តិបន្តបន្ទាប់គ្នា ទទួលបានសន្ទស្សន៍ ៤%

**ប្រការ ៧.-**

ការគណនាប្រាក់សោធននិវត្តន៍ប្រចាំខែរបស់និវត្តជន ត្រូវអនុវត្តតាមរូបមន្ត ដូចខាងក្រោម៖

| | |
|---|---|
| ប្រាក់សោធននិវត្តន៍ប្រចាំខែ = | ប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងក្នុងរយៈពេលមួយឆ្នាំនៃឆ្នាំណាមួយ ដែលមានចំនួនទឹកប្រាក់អតិបរមា x សន្ទស្សន៍ |

ប្រាក់សោធននិវត្តន៍ប្រចាំខែ អាចប្រែប្រួលបានទៅតាមប្រាក់បំណាច់ និងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាងនៃថវិកាប្រចាំឆ្នាំអតិបរមា ដោយមិនគិតជានិវត្តជនមុន ឬនិវត្តជនក្រោយឡើយ។

**ប្រការ ៨.-**

អតីតសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលមានអាយុក្រោម ៦០ (ហុកសិប) ឆ្នាំ អាចស្នើសុំប្រាក់សោធននិវត្តន៍បាន នៅពេលមានអាយុគ្រប់ ៦០ (ហុកសិប) ឆ្នាំ ដោយត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៣ នៃសេចក្ដីសម្រេចនេះ។

**ប្រការ ៩.-**

របៀបគិតអតីតភាពការងាររបស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គឺមានដូចតទៅ៖

- ត្រូវរាប់បញ្ចូលអតីតភាពការងារជាសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត នូវអតីតភាពការងារដែលនិវត្តជនបានធ្វើជាតំណាងរាស្ត្រ ឬ/និងសមាជិកព្រឹទ្ធសភា ឬ/និងសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ
- មានអតីតភាពចាប់ពី ១៦ ថ្ងៃឡើងទៅ ត្រូវគិតស្មើ ១ ខែ
- មានអតីតភាពចាប់ពី ៦ ខែឡើងទៅ ត្រូវគិតស្មើ ១ ឆ្នាំ

## ផ្នែកទី ២
## បែបបទនៃការផ្ដល់ប្រាក់សោធននិវត្តន៍

**ប្រការ ១០.-**

សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅពេលចប់អាណត្តិ ហើយដល់អាយុចូលនិវត្តន៍ដែលមិនត្រូវបានជ្រើសតាំងបន្តទៀត ត្រូវដាក់ពាក្យសុំចូលនិវត្តន៍ នៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

ការដាក់ពាក្យសុំចូលនិវត្តន៍ ត្រូវបំពេញ និងភ្ជាប់មកជាមួយនូវឯកសារមួយចំនួន ដូចខាងក្រោម៖

- ពាក្យសុំចូលនិវត្តន៍ ចំនួន ២ (ពីរ) ច្បាប់
- សលាកបត្រព័ត៌មានសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចូលនិវត្តន៍
- ច្បាប់ថតចម្លងព្រះរាជក្រឹត្យតែងតាំងសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ/និងព្រះរាជក្រឹត្យបញ្ចប់មុខតំណែងសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
- លិខិតយល់ព្រមបោះបង់ប្រាក់សោធននិវត្តន៍នៅក្រសួង ស្ថាប័នណាមួយ (បើមាន)
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ច្បាប់ថតចម្លង)
- សៀវភៅគ្រួសារ (ច្បាប់ថតចម្លង)

**ប្រការ ១១.-**

ក្រោយពីបានទទួលពាក្យសុំចូលនិវត្តន៍របស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការពិនិត្យ និងផ្ទៀងផ្ទាត់ព័ត៌មានក្នុងពាក្យសុំចូលនិវត្តន៍ និងឯកសារភ្ជាប់មកជាមួយរបស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ៥ (ប្រាំ) ថ្ងៃបន្ទាប់ពីថ្ងៃបានទទួលពាក្យសុំ ដើម្បីដាក់ជូនគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យ សម្រេច។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើពាក្យសុំចូលនិវត្តន៍ ក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលសំណុំឯកសារពាក្យសុំចូលនិវត្តន៍របស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពីអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ផ្នែកទី ៣
## នីតិវិធីនៃការផ្ដល់ប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាព

**ប្រការ ១២.-**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបើកផ្ដល់ប្រាក់សោធននិវត្តន៍ដល់និវត្តជនជាសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឱ្យបានទាន់ក្នុងសប្ដាហ៍ទី ៤ នៃខែនីមួយៗ តាមរយៈប្រព័ន្ធធនាគារ។

**ប្រការ ១៣.-**

និវត្តជនជាអតីតសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនៅពេលជាប់ជាតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ មិនត្រូវបានបើកផ្ដល់ប្រាក់សោធននិវត្តន៍ទេ។ ក្នុងករណីនេះ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្អាកការបើកផ្ដល់ប្រាក់សោធននិវត្តន៍ជាបន្ទាន់។

នៅពេលចប់អាណត្តិ ជាតំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សាមីជនអាចសម្រេចសាជាថ្មីថាយកប្រាក់សោធននិវត្តន៍តំណាងរាស្ត្រ ឬសមាជិកព្រឹទ្ធសភា ឬសមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ឬប្រាក់សោធននិវត្តន៍សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ប្រការ ១៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ថវិកាចំនួន ៥០,០០០,០០០ (ហាសិបលាន) រៀល សម្រាប់រៀបចំពិធីបុណ្យសព ក្នុងករណីដែលសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលមរណភាពនៅក្នុងអាណត្តិ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗគ្រប់យ៉ាង ដល់គ្រួសារសពចំនួន ១២ ខែ របស់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលទទួលមរណភាពក្នុងអាណត្តិ។

ប្រាក់បំណាច់ ព្រមទាំងប្រាក់ឧបត្ថម្ភផ្សេងៗជូនដល់គ្រួសារសពក្នុងកថាខណ្ឌទី២ ខាងលើ អាចត្រូវបានបើកផ្ដាច់ ប្រសិនបើមានការស្នើសុំពីគ្រួសារសព។

**ប្រការ ១៥.-**

នៅពេលនិវត្តជនសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទទួលមរណភាព គ្រួសារនៃសពត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់ប្រាក់ឧបត្ថម្ភមួយលើក ចំនួន ១២ ខែ លើប្រាក់សោធននិវត្តន៍សរុបប្រចាំខែរបស់សាមីជន។

## ជំពូកទី ៣
## ភារកិច្ច និងសមត្ថកិច្ចគ្រប់គ្រងប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាព

**ប្រការ ១៦.-**

ជារៀងរាល់ឆ្នាំ ក្រោមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលើកគម្រោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពសម្រាប់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលចូលនិវត្តន៍ និងទទួលមរណភាព ដើម្បីដាក់ឆ្លងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យ សម្រេចបញ្ចូលក្នុងថវិកាប្រចាំឆ្នាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ប្រការ ១៧.-**

ការបើកប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពរបស់និវត្តជនសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាសមត្ថកិច្ចអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

## ជំពូកទី ៤
## អន្តរប្បញ្ញត្តិ

**ប្រការ ១៨.-**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំគម្រោងផែនការស្ថិតិ និងថវិកាប្រាក់សោធននិវត្តន៍ និងប្រាក់ឧបត្ថម្ភមរណភាពសម្រាប់សមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលគ្រប់លក្ខខណ្ឌចូលនិវត្តន៍ និងទទួលមរណភាព ដើម្បីដាក់ឆ្លងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យ សម្រេចបញ្ចូលក្នុងគម្រោងថវិកាឆ្នាំ២០១៩ របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត។

**ប្រការ ១៩.-**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើបច្ចុប្បន្នភាព និងរៀបចំសេចក្តីជូនដំណឹងចំពោះអតីតសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដែលបានតែងតាំងក្នុងចន្លោះពេលចាប់ពីឆ្នាំ១៩៩៨ ដល់ឆ្នាំ២០១៨ ហើយដល់អាយុចូលនិវត្តន៍ដែលមិនត្រូវបានជ្រើសតាំងបន្តទៀតឱ្យមកដាក់ពាក្យសុំចូលនិវត្តន៍ ឱ្យបានមុនដំណាច់ខែមីនា ឆ្នាំ២០១៨ ដើម្បីដាក់ឆ្លងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យសម្រេច។

## ជំពូកទី ៥
## អវសានប្បញ្ញត្តិ

**ប្រការ ២០.-**

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងនិវត្តជនជាសមាជិក សមាជិកាគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃច័ន្ទ ១១រោច ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១២ ខែមីនា ឆ្នាំ២០១៨

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ស៊ិក ប៊ុនហុក**

**ចម្លងជូន៖**

- សមាជិក គ.ជ.ប
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ "ដើម្បីជូនជ្រាប"
- ដូចប្រការ ២០ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ